EAT 5 A DAY for better health

fruits and vegetables

ការផ្តល់ជំនួយអាហារបំប៉ន
ដល់មនុស្សគ្រប់អាយុ

## ពាក្យសុំសម្រាប់

# ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ

សូមធ្វើតាមជំហានសាមញ្ញទាំងនេះដើម្បីស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ ។
**សម្គាល់:** ប្រសិនបើលោកអ្នកពិការ ឬ ត្រូវការជំនួយបំពេញពាក្យសុំនេះ សូមឱ្យបុគ្គលិកដឹង នោះមនុស្សម្នាក់នឹងជួយលោកអ្នក ។

**ជំហាន 1:** សូមបំពេញនូវរាល់ចំណុចក្នុងពាក្យសុំនេះឱ្យបានកាន់តែច្រើនដូចដែលលោកអ្នកអាចបំពេញបាន រួចចុះហត្ថលេខាលើទំព័រទី ១ បន្ទាប់មកបញ្ជូនវាត្រឡប់ទៅការិយាល័យ ប័ណ្ណអាហារូបត្ថម្ភក្នុងតំបន់ ។ យើងត្រូវការយ៉ាងហោចណាស់ក៏ឈ្មោះ, អាស័យដ្ឋាន និង ហត្ថលេខារបស់លោកអ្នក ។
**ប្រសិនបើលោកអ្នកត្រូវការតែអាហារ ដោយមិនត្រូវការប្រាក់ លោកអ្នកអាចទទួលផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភបន្ទាន់ក្នុងពេលបី (៣) ថ្ងៃ ។ លោកអ្នកត្រូវឆ្លើយសំណួរដែលមានគូសសញ្ញា (✔) ទាំងអស់ លើគ្រប់ទំព័រទាំងអស់ ។**

**ជំហាន 2:** លោកអ្នកនឹងត្រូវគេរៀបចំកាលវិភាគដើម្បីសម្ភាសន៍ជាមួយបុគ្គលិកប័ណ្ណអាហារូបត្ថម្ភ ដែលនឹងមើលពាក្យសុំនេះជាមួយលោកអ្នក ហើយ នឹងសួរលោកអ្នកនូវសំណួរជាច្រើន ដើម្បីបំពេញលើដំណើរការរបស់ពាក្យសុំនេះ ។

**ជំហាន 3:** លោកអ្នកត្រូវតែនាំមកជាមួយនឹងការបញ្ជាក់ពីអត្តសញ្ញាណ និង ចំណូល នៅក្នុងការសម្ភាសន៍របស់លោកអ្នក ។ លោកអ្នកគួរតែនាំមកជាមួយនូវរបស់ផ្សេងទៀតផងដែរ ដូចជា វិក័យប័ត្រជួល, វិក័យប័ត្រទឹកភ្លើង ឬ ក្រដាស់បង់ប្រាក់ការងារ ។ ប្រសិនបើលោកអ្នកមិនរាយការណ៍ និង ផ្តល់ការបញ្ជាក់ពីការចំណាយ នោះនឹងគ្មានការកាត់នូវចំណាយទាំងនោះពីចំណូលរបស់លោកអ្នកឡើយ ។

## ព័ត៌មានសំខាន់សម្រាប់ជនអន្តោប្រវេសន៍

- លោកអ្នកអាចស្នើសុំ និង ទទួលផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភសម្រាប់សមាជិកដែលទទួលសិទ្ធិ សូម្បីតែគ្រួសាររបស់លោកអ្នកមានរួមបញ្ចូលសមាជិកផ្សេងទៀតដែលមិនទទួលសិទ្ធិ ដោយសារតែឋានៈអន្តោប្រវេសន៍ ។ ឧទាហរណ៍ ឪពុកម្តាយអន្តោប្រវេសន៍អាចស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភសម្រាប់កូនដែលមានសញ្ជាតិអាមេរិក ឬ កូនអន្តោប្រវេសន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទោះបីជា ឪពុកម្តាយអាចមិនទទួលសិទ្ធិសម្រាប់ផលប្រយោជន៍ទាំងនោះ ។
- លោកអ្នកមិនចាំបាច់ផ្តល់នូវព័ត៌មានឋានៈអន្តោប្រវេសន៍, លេខសុវត្ថិភាពសង្គម ឬ ឯកសារ ចំពោះសមាជិកគ្រួសារណាម្នាក់ដែលមិនទទួលសិទ្ធិសម្រាប់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ ដោយសារតែឋានៈអន្តោប្រវេសន៍ និង អ្នកមិនសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ ។
- ការប្រើប្រាស់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភនឹងមិនជះឥទ្ធិពលដល់ឋានៈអន្តោប្រវេសន៍របស់លោកអ្នក ឬ ឋានៈអន្តោប្រវេសន៍របស់គ្រួសារលោកអ្នកឡើយ ។ ព័ត៌មានអន្តោប្រវេសន៍គឺឯកជន និង សម្ងាត់ ។

## ការស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ

# ការណែនាំ និង ព័ត៌មានដំប្រយោជន៍

*សូមអានព័ត៌មានខាងក្រោម - គ្មានអ្វីដែលត្រូវបំពេញលើទំព័រនេះទេ។*

## អ្វីដែលយើងមានន័យនៅពេលយើងនិយាយ

*ដើម្បីជួយលោកអ្នកឱ្យយល់ពីពាក្យមួយចំនួនដែលប្រើប្រាស់នៅក្នុងពាក្យសុំនេះ និង នៅពេល សម្ភាសន៍ សូមយោងទៅនិយ័មន័យខាងក្រោម :*

**លោកអ្នក, នណាម្នាក់, មនុស្សគ្រប់រូប** — នណាម្នាក់ ឬ មនុស្សគ្រប់រូបទាំងអស់ដែលរស់នៅក្នុងផ្ទះរបស់លោកអ្នក និង ដែលកំពុងស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ។ ពេលយើងត្រូវការព័ត៌មានអំពីមនុស្សផ្សេងទៀតនៅក្នុងផ្ទះរបស់លោកអ្នក យើងនឹងសួរលោកអ្នក។

**គ្រួសាររបស់លោកអ្នក** — មនុស្សដែលរស់នៅក្នុងផ្ទះ ដែលជាអ្នកទិញ និង ធ្វើម្ហូបអាហាររួមគ្នា និង កំពុងស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ។

**ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ** — ផលប្រយោជន៍សម្រាប់គ្រួសារដែលមានចំណូលទាបដើម្បីជួយទិញម្ហូបអាហារ។

**សេវាកម្មប័ណ្ណអាហារូបត្ថម្ភរហ័ស** — ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភដែលអាចមានសម្រាប់លោកអ្នកក្នុងរយៈពេលបី (៣) ថ្ងៃ។

**ធនធាន** — ប្រាក់ដែលលោកអ្នកមាន ដូចជា :

- ប្រាក់ក្នុងដៃ, មូលប្បទានប័ត្រដែលមិនអាចប្តូរជាសាច់ប្រាក់, ប្រាក់នៅក្នុងគណនីចរន្ត, គណនីសន្សំ ឬ លិខិតបញ្ជាក់សន្សំ -ល-។
- លិខិតកើ្តមរតក, លិខិតទារបំណុល, ប័ណ្ណភាគហ៊ុន ឬ សញ្ញាប័ណ្ណ -ល-។

**ទឹកភ្លើង** — ហ្គាស, ភ្លើង, កម្តៅ, ឥន្ទនៈ, ទូរស័ព្ទ (អត្រាមូលដ្ឋាន), ការតម្លើងទឹកភ្លើង, ការប្រមូលសម្រាម និង សំណល់, ទឹក, លូ -ល-។

**ចំណូល** — ប្រាក់ដែលទទួលបាន ឬ សង្ឃឹមថាទទួលក្នុងខែនេះ ដូចជា :

- ចំណូល, សុខមាលភាព, ឧបត្ថម្ភក្មេង, SSI ឬ សុវត្ថិភាពសង្គម, ឬ ការបង់ប្រាក់សម្រាប់ទាហានជើងចាស់
- ប្រាក់សោធននិវត្តន៍ ឬ ការបង់ប្រាក់សម្រាប់ចូលនិវត្តន៍
- និកម្មភាព (UIB), ពិការភាពរដ្ឋ (SDI) ឬ ពិការភាពផ្សេងទៀត
- មូលនិធិកូដកម្ម, ការបង់ប្រាក់ពីអ្នកជួលបន្ទប់, ប្រាក់ជំនួយ និង កម្ចីរបស់សាលា
- អំណោយជាសាច់ប្រាក់, ការឈ្នះជាសាច់ប្រាក់ ឬ ការបង់ជាសាច់ប្រាក់ផ្សេងទៀត

**ជំនួយជាសាច់ប្រាក់** — ឱកាសការងារ និង ការទទួលខុសត្រូវចំពោះក្មេង នៅរដ្ឋកាលីហ្វ័រញ៉ា (កាលវើក), ជំនួយជនភាសខ្លួន ឬ កម្មវិធីជំនួយសាច់ប្រាក់ក្នុងតំបន់នៅស្រុករបស់លោកអ្នក [ជំនួយទូទៅ ឬ ការផ្តល់ឱ្យទូទៅ (GA/GR) ឬ កម្មវិធីជំនួយសាច់ប្រាក់សម្រាប់ជនអន្តោប្រវេសន៍ (CAPI)]។

## រឿងផ្សេងទៀតដែលលោកអ្នកគួរដឹង

- **លោកអ្នកអាចមានចម្ងល់ពីមូលហេតុដែលយើងសួរសំនួរមួយចំនួន។ សំណួរទាំងអស់គឺតម្រូវដោយច្បាប់សហព័ន្ធ/រដ្ឋ ដើម្បីកំណត់ពីភាពទទួលសិទ្ធិរបស់លោកអ្នកសម្រាប់ផលប្រយោជន៍អាហារូបត្ថម្ភ។**
- លោកអ្នកអាចស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ និង ជំនួយជាសាច់ប្រាក់នៅពេលជាមួយគ្នា និង មានតែការសម្ភាសន៍ម្តង សម្រាប់ទាំងពីរមុខ លើកលែងតែពេលដែលលោកអ្នកស្នើសុំ GA/GR ជាជំនួយសាច់ប្រាក់។
- ប្រសិនបើផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភរបស់លោកអ្នក, ឯកសារទទួលសិទ្ធិ (AD) ឬ ប័ណ្ណធានារ៉ាប់រង បានបាត់តាមការផ្ញើសំបុត្រ លោកអ្នកត្រូវតែរាយការណ៍ពីវា មុនចុងខែដែលលោកអ្នកគួរតែទទួលបានវា។ ប៉ុន្តែ ប្រសិនបើពួកវាត្រូវបានលួច ឬ បំផ្លាញ លោកអ្នកត្រូវតែរាយការណ៍ពីការបាត់បង់របស់លោកអ្នក ក្នុងរយៈពេលដប់ (១០) ថ្ងៃនៃឧប្បត្តិហេតុ។
- ប្រសិនបើលោកអ្នកទទួលផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភច្រើនពេក លោកអ្នកនឹងត្រូវសងវាត្រឡប់មកវិញ និង/ឬ ផលប្រយោជន៍ទាំងនោះនឹងត្រូវបានបន្ទាប ឬ បញ្ឈប់។ លេខសុវត្ថិភាពសង្គម (SSN) របស់លោកអ្នក អាចត្រូវបានប្រើប្រាស់ដើម្បីប្រមូលចំនួននៃផលប្រយោជន៍ដែលជំពាក់, តាមរយៈតុលាការ, ទីភ្នាក់ងារប្រមូលផ្សេងទៀត និង សម្រាប់ សកម្មភាពប្រមូលរបស់រដ្ឋាភិបាលសហព័ន្ធ។
- SSN របស់លោកអ្នកនឹងត្រូវបានគេប្រើប្រាស់ដើម្បីពិនិត្យអត្តសញ្ញាណ ដើម្បីបង្កាការចូលរួមជាន់គ្នា និង ដើម្បីបញ្ជាក់ពីភាពទទួលសិទ្ធិ និង ផលប្រយោជន៍។ SSN នឹងត្រូវបានប្រើនៅក្នុងការផ្គូផ្គងក្នុងកុំព្យូទ័រដើម្បីពិនិត្យពីចំណូលរបស់លោកអ្នក និង ធនធានជាមួយកំណត់ត្រាពីពន្ធដា, សុខមាលភាព, ការងារ និង រដ្ឋបាលសុវត្ថិភាពសង្គម និង ភ្នាក់ងារផ្សេងទៀត។ ភាពខុសគ្នាអាចត្រូវបានត្រួតពិនិត្យជាមួយលោកអ្នក និង ជាមួយនិយោជក, ធនាគារ និង កន្លែងផ្សេងទៀត។ ការចូលរួមដែលលួចបន្លំនៅក្នុងកម្មវិធីប័ណ្ណអាហារូបត្ថម្ភអាចមានលទ្ធផលជាបទឧក្រិដ្ឋ ឬ រដ្ឋប្បវេណី ឬ ការប្តឹងបែបរដ្ឋបាល។
- ការផ្តល់ SSN របស់លោកអ្នក គឺមិនត្រូវការ នៅពេលលោកអ្នកប្រគល់ពាក្យសុំជាលើកដំបូង។ ទោះជាយ៉ាងនេះក្តី លោកអ្នកនឹងត្រូវស្នើសុំឱ្យផ្តល់ព័ត៌មានមកយើងដើម្បីគូសបញ្ជាក់ពីភាពទទួលសិទ្ធិ និង ផលប្រយោជន៍សម្រាប់សមាជិកផ្សេងទៀតនៅក្នុងគ្រួសាររបស់លោកអ្នក។ ជាធម្មតាលោកអ្នកត្រូវផ្តល់ឱ្យយើងនូវ SSN របស់លោកអ្នក ឬ ការបញ្ជាក់ពីពាក្យសុំសម្រាប់ SSN របស់លោកអ្នក មុនពេលយើងអាចផ្តល់ជូនលោកអ្នកនូវផលប្រយោជន៍ផ្សេងៗ។ យើងអាចបដិសេធលោកអ្នក ឬ សមាជិកណាម្នាក់ដែលទទួលបានផលប្រយោជន៍ជាគ្រួសារ សម្រាប់ការខកខានក្នុងការផ្តល់ SSN។

## ការប្តឹង និង សវនាការរដ្ឋ

ប្រសិនបើលោកអ្នកមានការប្តឹង សូមព្យាយាមធ្វើវានៅស្រុករបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនអាចធ្វើបាន លោកអ្នកអាចទូរស័ព្ទ ឬ សរសេរទៅ :

California Department of Social Services<br>
744 P Street, MS 8-16-50<br>
Sacramento, CA 95814<br>
លេខទូរស័ព្ទ : 1-800-952-5253<br>
ឬ សម្រាប់មនុស្សថ្លង់ ឬ គ សូមទូរស័ព្ទទៅលេខ<br>
1-800-952-8349

ប្រសិនបើលោកអ្នកគិតថាសកម្មភាពណាមួយដែលធ្វើឡើងដោយស្រុកគឺខុស លោកអ្នកអាចស្នើសុំសវនាការរបស់រដ្ឋដោយសរសេរផ្ញើទៅការិយាល័យសុខមាលភាពរបស់ស្រុកក្នុងតំបន់របស់លោកអ្នក ឬ ដោយទូរស័ព្ទទៅលេខទូរស័ព្ទដែលមានរាយខាងលើ។ លោកអ្នកត្រូវតែស្នើសុំសវនាការក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ នៃសកម្មភាពនោះ និង ប្រាប់ពីមូលហេតុដែលលោកអ្នកចង់ធ្វើដូច្នេះ។

ច្បាប់ថ្លែងថាអ្នកដាក់ពាក្យសុំ/អ្នកទទួលទាំងអស់ នូវ ជំនួយ, ផលប្រយោជន៍ ឬ សេវាកម្មនឹងត្រូវបានចាត់ទុកដោយយុត្តិធម៌ ដោយមិនគិតពីជាតិសាសន៍, ពណ៌សម្បុរ, ជាតិកំណើត, ការជាប់ទាក់ទងក្នុងនយោបាយ, សាសនា, ឋានៈរៀបការ, ភេទ, អាយុ ឬ ពិការភាព។

ប្រសិនបើលោកអ្នកគិតថាលោកអ្នកត្រូវបានគេរើសអើង លោកអ្នកអាចដាក់ពាក្យបណ្តឹងដោយ :

1. ទាក់ទងអ្នកសម្របសម្រួលសិទ្ធិប្រជាពលរដ្ឋនៅស្រុករបស់លោកអ្នក ឬ
2. សរសេរទៅ ឬ ទូរស័ព្ទទៅ :<br>
   The state's Civil Rights Bureau, M.S. 18-16-70,<br>
   P.O. Box 944243, Sacramento, CA 94244-2430<br>
   1-866-741-6241 (ទូរស័ព្ទឥតបង់ប្រាក់)
3. *ឬ សម្រាប់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភប៉ុណ្ណោះ សូមសរសេរទៅ :*<br>
   Secretary of Agriculture<br>
   U.S. Department of Agriculture<br>
   14th & Independence Avenue, S.W.<br>
   Room 200A<br>
   Administration Building<br>
   Washington, D.C.  20250

# ពាក្យសុំសម្រាប់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ

## ព័ត៌មានអ្នកស្នើសុំ

1. សូមបំពេញព័ត៌មានផ្ទាល់ខ្លួនខាងក្រោម សម្រាប់មនុស្សដែលបានស្នើសុំផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ ។

| | |
|---|---|
| ឈ្មោះ (គោត្តនាម, នាម, នាមកណ្តាល) | |
| លេខទូរស័ព្ទ (រួមបញ្ចូលទាំងលេខកូដតំបន់) | |
| អាស័យដ្ឋានទីលំនៅ (ផ្លូវ, ប្រអប់សំបុត្រ, លេខអាគារជួល,) | |
| ក្រុង, រដ្ឋ, លេខកូដតំបន់ | |
| អាស័យដ្ឋានផ្ញើសំបុត្រ (ប្រសិនបើខុសពីខាងលើ) | |
| ក្រុង, រដ្ឋ, លេខកូដតំបន់ | |

2. ការិយាល័យប័ណ្ណអាហារូបត្ថម្ភអាចផ្តល់ជូននូវអ្នកបកប្រែដល់លោកអ្នកដោយមិនគិតថ្លៃ ។ តើលោកអ្នកត្រូវការអ្នកបកប្រែនៅពេលសម្ភាសន៍លោកអ្នក?
☐ បាទ/ចាំ ☐ ទេ ប្រសិនបើ "បាទ/ចាំ" ភាសាអ្វី? ______________

3. ដើម្បីជួយយើងធ្វើឱ្យសេវាកម្មរបស់ពួកយើងកាន់តែប្រសើរសម្រាប់លោកអ្នក សូមបំពេញ A និង B ខាងក្រោម ។ ចូរគូសក្នុងប្រអប់ចំពោះព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងខ្លួនអ្នក ។ ច្បាប់ចែងថា មនុស្សគ្រប់រូបត្រូវកត់ត្រាពីក្រុមជាតិសាសន៍ សញ្ជាតិ និងភាសាររបស់ខ្លួន ។ ប្រសិនបើអ្នកមិនបំពេញព័ត៌មាននេះទេ សមត្ថកិច្ចពាក់ព័ន្ធនឹងជួយបំពេញព័ត៌មានជូនអ្នក ។ ការជួយបំពេញនេះមិនប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកក្នុងការទទួលប្រាក់ឧបត្ថម្ភអាហារឡើយ ។

A. **ជាតិសាសន៍ (ជនគ្រប់រូបត្រូវបំពេញព័ត៌មាននៅចំណុច B)**

តើអ្នកមានសញ្ជាតិហ៊ីស្ប៉ាញ ឬឡាទីនមែនទេ? ☐ បាទ/ចាំ ☐ ទេ

B. **ក្រុមជាតិសាសន៍** – ☐ ស្បែកស ☐ អ៊ីស្លាទីក ☐ ស្បែកខ្មៅ ☐ ហ្វីលីពីន ☐ ចិន
☐ ឥណ្ឌាជនជាតិដើមអាមេរិក ឬ ជនជាតិដើមអាឡាស្កា ☐ ជប៉ុន ☐ កូរ៉េ ☐ ហ្គាម៉ាន ☐ សាម៉ូន
☐ វៀតណាម ☐ ឥណ្ឌាអាស៊ី ☐ ឡាវ ☐ ហាវ៉ៃ
☐ ជនជាតិអាស៊ី ឬ ជនលើដីកោះផាស៊ីហ្វិក ផ្សេងទៀត (*សូមបញ្ជាក់*)______________

C. **ភាសាចំបង** – ☐ អង់គ្លេស ☐ អេស្ប៉ាញ ☐ ឡាវ ☐ តាហ្គាឡុក
☐ សញ្ញារបស់ជនជាតិអាមេរិក ☐ ចិនកាតាំង ☐ ខ្មែរ ☐ វៀតណាម ☐ រ៉ូស៊ី
☐ ផ្សេងទៀត (*សូមបញ្ជាក់*)______________

✔4. នណាម្នាក់នៅក្នុងគ្រួសារគឺ : (សូមគូសលើសពីមួយប្រសិនបើត្រូវ)

☐ ពិការ
☐ ជរា (៦០ និង ចាស់ជាងនេះ)
☐ គ្មានប្រាក់សម្រាប់អាហារ
☐ គ្មានផ្ទះ
☐ ជនអន្តោប្រវេសន៍/កម្មករកសិដ្ឋានតាមរដូវ
ទទួលការបញ្ឈប់ចំណូលតែមួយគត់របស់លោកអ្នក? ☐ បាទ/ចាំ ☐ ទេ

✔5. តើលោកអ្នកមានស្ថានភាពរាងកាយ ឬ ខួរក្បាលដែលទាមទារជំនួយពិសេសក្នុងអំឡុងពេលនៃការសម្ភាសន៍របស់លោកអ្នកជាមួយនឹងបុគ្គលិកប័ណ្ណអាហារូបត្ថម្ភ? ☐ បាទ/ចាំ ☐ ទេ

✔6. តើថ្លៃជួល ឬ បញ្ចាំរបស់លោកអ្នកប៉ុន្មានក្នុងខែនេះ? $______________

✔7. តើថ្លៃចំណាយទឹកភ្លើងរបស់លោកអ្នកប៉ុន្មានក្នុងខែនេះ ប្រសិនបើគិតដោយឡែកពី ថ្លៃជួល ឬ បញ្ចាំ? $______________

**ខ្ញុំបានទទួលដំណឹងអំពីការទទួលផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភបន្ទាន់ក្នុងរយៈពេលបី (៣) ថ្ងៃ។**

______________________________ ______________________________
ហត្ថលេខា កាលបរិច្ឆេទ

សម្រាប់ស្រុកប្រើប៉ុណ្ណោះ

**Case Name** ______________________________ **Case #** ______________
**Application Type:** ☐ **New** ☐ **Recert** **Date received by County** ______________
**Screened for Expedited Service (ES)?** ☐ **Yes** ☐ **No** **ES Eligible** ☐ **Yes** ☐ **No**

# ពាក្យសុំសម្រាប់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ

## ព័ត៌មានគ្រួសារ

8. សូមបំពេញព័ត៌មានខាងក្រោមសម្រាប់គ្រប់មនុស្សទាំងអស់នៅក្នុងផ្ទះ រួមទាំងខ្លួនលោកអ្នកផ្ទាល់ ។ ស្រុកនឹងប្រើប្រាស់ព័ត៌មាននេះដើម្បីកំណត់ភាពទទួលសិទ្ធិរបស់លោកអ្នកតែប៉ុណ្ណោះ ។

| ឈ្មោះ (គោត្តនាម, នាម, នាមកណ្តាល) | លេខសុវត្ថិភាពសង្គម (ប្រសិនបើគ្មាន សូមសរសេរគ្មាន) | ទំនាក់ទំនង (ដូចជា កូនប្រុស, ភរិយា មិត្តភ័ក្រ, កូនចិញ្ចឹម -ល-) | គូសរង្វង់មួយ | ថ្ងៃខែឆ្នាំកំណើត | តើលោកអ្នកទិញ និង ធ្វើម្ហូបអាហារជាមួយមនុស្សនេះ? (គូសរង្វង់មួយ) |
|---|---|---|---|---|---|
| 1. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 2. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 3. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 4. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 5. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 6. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 7. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 8. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 9. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |
| 10. | | | ប្រុស/ស្រី | | បាទ-ចាំ /ទេ |

## ចំណូល និង ការងារ

✔ 9. តើលោកអ្នកមាន ឬ នឹងទទួលបានចំណូលខ្លះក្នុងខែនេះ? ☐ បាទ/ចាំ ☐ ទេ

សូមរាយចំណូលគ្រួសាររបស់លោកអ្នកខាងក្រោម :

| ឈ្មោះអ្នកដែលទទួលប្រាក់ | ប៉ុន្មានក្នុងខែនីមួយៗ? |
|---|---|
| | $ |
| | $ |
| | $ |
| | $ |

## ធនធាន

✔ 10. តើលោកអ្នកមានប្រាក់ប៉ុន្មាន? នេះរួមទាំងប្រាក់នៅក្នុងគណនីធនាគារ, ក្នុងផ្ទះរបស់លោកអ្នក ឬ នៅកន្លែងផ្សេងទៀត ។

$ ____________________

សម្រាប់ស្រុកប្រើប៉ុណ្ណោះ

# ពាក្យសុំសម្រាប់ផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភ

## ព័ត៌មានសំខាន់

- ➤ ក្រសួង កសិកម្មសហរដ្ឋអាមេរិក (USDA) ហាមឃាត់ការរើសអើងនៅក្នុងកម្មវិធី និង សកម្មភាពរបស់ខ្លួនទាំងអស់ លើមូលដ្ឋានពូជសាសន៍, ពណ៌សម្បុរ, ភេទ, សាសនា, ជាតិដើម ឬ ជំនឿនយោបាយ ។ លោកអ្នកអាចដាក់ពាក្យបណ្ដឹង ប្រសិនបើលោកអ្នកគិតថាលោកអ្នកត្រូវបានគេរើសអើង ។ ប្រសិនបើលោកអ្នកមិនយល់ព្រមជាមួយការសម្រេចរបស់ស្រុក ការប្ដឹងឧទ្ធរអាចមានសម្រាប់លោកអ្នក ។
- ➤ ព័ត៌មានលើពាក្យសុំនេះអាចត្រូវបានចែករំលែកជាមួយសហព័ន្ធ, រដ្ឋ និង ភ្នាក់ងារក្នុងតំបន់ តែក្នុងគោលបំណងនៃការពិនិត្យបញ្ជាក់លើភាពទទួលសិទ្ធិពីកម្មវិធីប័ណ្ណអាហារូបត្ថម្ភប៉ុណ្ណោះ ។ ដំណើរការនេះអាចរួមបញ្ចូលការបញ្ជាក់ជាមួយនឹង ផ្នែកសេវាកម្មសញ្ជាតិ និង អន្តោប្រវេសន៍សហរដ្ឋអាមេរិក (USCIS) (ពីមុន INS) នៃឋានៈអន្តោប្រវេសន៍ ចំពោះតែអ្នកដែលស្វែងរកផលប្រយោជន៍ប័ណ្ណអាហារូបត្ថម្ភប៉ុណ្ណោះ ។ ច្បាប់សហព័ន្ធថ្លែងថា USCIS មិនអាចប្រើប្រាស់ព័ត៌មាននេះសម្រាប់អ្វីៗទាំងអស់ លើកលែងតែករណីនៃការលួចបន្លំ ។

## ហត្ថលេខា

ខ្ញុំសូមបញ្ជាក់ក្រោមការផ្ដន្ទាទោសចំពោះការភូតភរ តាមច្បាប់នៃសហរដ្ឋ អាមេរិក និង រដ្ឋ កាលីហ្វ័រញ៉ា ថាព័ត៌មានដែលខ្ញុំបានផ្ដល់ឱ្យនៅក្នុងពាក្យសុំនេះគឺ ពិត, ត្រឹមត្រូវ និង ពេញលេញ ។

| | |
|---|---|
| ហត្ថលេខា (សមាជិកគ្រួសារពេញវ័យ ឬ អ្នកតំណាងដែលទទួលសិទ្ធិ) | កាលបរិច្ឆេទ |
| ហត្ថលេខារបស់សាក្សី ឬ អ្នកបកប្រែ | កាលបរិច្ឆេទ |
| ហត្ថលេខានៃបុគ្គលិកដែលទទួលសិទ្ធិ | កាលបរិច្ឆេទ |